Stanford University	**យល់ព្រមចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវ** (Consent to Participate in Research) [Khmer]	TEM-C-5khm

អ្នកត្រូវបានស្នើឱ្យចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវមួយ។ ឈ្មោះការសិក្សាស្រាវជ្រាវ៖

_____

_____

_____

_____

_____

យើងនឹងផ្តល់ជូនអ្នកនូវព័ត៌មានសំខាន់ៗសម្រាប់ការសិក្សាស្រាវជ្រាវនេះ។ មុនពេលយល់ព្រម, អ្នកសិក្សាស្រាវជ្រាវត្រូវតែប្រាប់អ្នកអំពី (i) គោលបំណង នីតិវិធី និងរយៈពេលនៃការសិក្សាស្រាវជ្រាវ, (ii) នីតិវិធីដែលធ្វើការពិសោធន៍, (iii) ហានិភ័យដែលព្យាករណ៍ដោយសមហេតុផល, អាការៈមិនស្រួល និងអត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវ, (iv) នីតិវិធី ឬការព្យាបាលជាជម្រើសផ្សេងទៀតដែលអាចមានប្រយោជន៍, (v) របៀបរក្សាការសម្ងាត់, និង (vi) ការប្រើប្រាស់ព័ត៌មាន ឬសំណាកជីវសាស្ត្ររបស់អ្នកនាពេលអនាគត។

ប្រសិនបើអាច, អ្នកសិក្សាស្រាវជ្រាវក៏ត្រូវតែប្រាប់អ្នកអំពី (i) សំណងអាចផ្តល់ជូន ឬការព្យាបាលក្នុងករណីមានរបួសកើតឡើង, (ii) ហានិភ័យដែលអាចកើតឡើងដោយមិនអាចដឹងមុន, (iii) កាលៈទេសៈដែលអ្នកសិក្សាស្រាវជ្រាវអាចនឹងបញ្ឈប់ការចូលរួមរបស់អ្នក, (iv) ការចំណាយបន្ថែមចំពោះអ្នក, (v) បញ្ហាដែលអាចកើតឡើង ប្រសិនបើអ្នកសម្រេចចិត្តឈប់ចូលរួម, (vi) នៅពេលដែលអ្នកទទួលបានលទ្ធផល រកឃើញថ្មីដែលអាចប៉ះពាល់ដល់គោលបំណងរបស់អ្នកនៅក្នុងការចូលរួម។ (vii) ចំនួនមនុស្សដែលចូលរួមនៅក្នុងការសិក្សា, (viii) ការប្រើប្រាស់សំណាកជីវសាស្ត្ររបស់អ្នកដើម្បីទទួលបានប្រាក់ចំណេញ, (ix) តើអ្នកនឹងទទួលបានព័ត៌មានអំពីលទ្ធផលស្រាវជ្រាវរបស់អ្នកឬទេ (x) តើការសិក្សាស្រាវជ្រាវអាចមានការរៀបលំដាប់ហ្សែនទាំងមូលដែរឬទេ, និង (xi) តើព័ត៌មានអំពីការសិក្សាស្រាវជ្រាវត្រូវបាន ឬនឹងត្រូវ ដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះសាកល្បងវេជ្ជសាស្ត្រដែរឬទេ។

ប្រសិនបើអ្នកយល់ព្រមចូលរួម, អ្នកនឹងទទួលបានឯកសារនេះចំនួនមួយច្បាប់ (ចុះហត្ថលេខាតាមការចាំបាច់) និងឯកសារសិក្សាស្រាវជ្រាវសង្ខេប ជាលាយលក្ខណ៍អក្សរជាភាសាអង់គ្លេស។

ប្រសិនបើអ្នកមានសំណួរ ការព្រួយបារម្ភ ឬការតវ៉ាអំពីការសិក្សាស្រាវជ្រាវនេះ, នីតិវិធីនៃការសិក្សាស្រាវជ្រាវ, ហានិភ័យ និងអត្ថប្រយោជន៍ ឬជម្រើសនៃការព្យាបាល, អ្នកគួរធ្វើការសាកសួរទៅកាន់

ប្រធានផ្នែកពិធីសារ _____

អ្នកអាចទាក់ទងទៅពួកគាត់នៅពេលនេះ ឬនៅពេលក្រោយតាមរយៈ: _____

ប្រសិនបើអ្នកមិនពេញចិត្តនឹងរបៀបនៃការសិក្សាស្រាវជ្រាវនេះ ឬប្រសិនបើអ្នកមានការព្រួយបារម្ភ ការតវ៉ា ឬសំណួរទូទៅណាមួយអំពីការសិក្សាស្រាវជ្រាវ ឬ អំពីសិទ្ធិរបស់អ្នកក្នុងនាមជាអ្នកចូលរួមនៅក្នុងសិក្សាស្រាវជ្រាវ សូមទាក់ទងទៅក្រុមប្រឹក្សាត្រួតពិនិត្យស្ថាប័ន Stanford (IRB) ដើម្បីរាយការណ៍ទៅបុគ្គលដែលមិនពាក់ព័ន្ធនឹងក្រុមស្រាវជ្រាវតាមរយៈលេខទូរសព្ទ (650)-723-5244 ឬទូរសព្ទឥតគិតថ្លៃ 1-866-680-2906។ អ្នកក៏អាចផ្ញើលិខិតទៅកាន់ Stanford IRB, Stanford University, 1705 El Camino Real, Palo Alto, CA 94306 ផងដែរ។

ការចូលរួមរបស់អ្នកនៅក្នុងការសិក្សាស្រាវជ្រាវនេះគឺជាការស្ម័គ្រចិត្ត ហើយអ្នកនឹងមិនត្រូវពិន័យ ឬបាត់បង់អត្ថប្រយោជន៍ណាមួយឡើយ ប្រសិនបើអ្នកបដិសេធមិនចូលរួម ឬសម្រេចចិត្តបញ្ឈប់ការចូលរួម។

នៅពេលចុះហត្ថលេខាលើឯកសារនេះគឺមានន័យថា ការសិក្សាស្រាវជ្រាវ រួមទាំងព័ត៌មានខាងលើត្រូវបានរៀបរាប់ឱ្យអ្នកស្តាប់ដោយផ្ទាល់មាត់ ហើយបញ្ជាក់ថាអ្នកយល់ព្រមចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវនេះដោយស្ម័គ្រចិត្ត។

ហត្ថលេខារបស់អ្នកចូលរួម/ តំណាងស្របច្បាប់/ ឪពុកម្តាយ ឬអាណាព្យាបាល /	*កាលបរិច្ឆេទ /*	*ហត្ថលេខារបស់សាក្សី (ឧ. បុគ្គលិក អ្នកបកប្រែ សមាជិកគ្រួសារ) /*	*កាលបរិច្ឆេទ /*
Signature of Participant/ Legally Authorized Representative/ Parent(s) or Guardian(s)	*Date*	*Signature of witness (e.g., staff, interpreter, family member)*	*Date*

សេចក្តីប្រកាសអំពីសិទ្ធិរបស់អ្នកចូលរួមក្នុងការធ្វើពិសោធន៍

(Experimental Subject's Bill of Rights)

ក្នុងនាមជាអ្នកចូលរួមនៅក្នុងការសិក្សាស្រាវជ្រាវ អ្នកមានសិទ្ធិដូចខាងក្រោម៖

សិទ្ធិរបស់អ្នកចូលរួមរួមមានជាអាទ៍ដូចខាងក្រោម៖

- ទទួលបានកាជូនដំណឹងអំពីលក្ខណ: និងគោលបំណងនៃការពិសោធន៍។
- ទទួលបានការពន្យល់អំពីនីតិវិធីដែលត្រូវអនុវត្តតាមនៅពិសោធន៍វេជ្ជសាស្ត្រ ព្រមទាំងឱសថ ឬឧបករណ៍ដែលត្រូវប្រើប្រាស់។
- ទទួលបានការរៀបរាប់ប្រាប់អំពីអាការ:មិនស្រួល និងហានិភ័យដែលរំពឹកទុកដោយសមហេតុផល។
- ទទួលបានការពន្យល់អំពីអត្ថប្រយោជន៍ដែលអាចមានសម្រាប់អ្នកចូលរួម ប្រសិនបើមាន។
- ទទួលបានការបង្ហាញអំពីជម្រើសសមស្របណាមួយ ឱសថ ឬឧបករណ៍ដែលអាចមានប្រយោជន៍ចំពោះអ្នកចូលរួម ហានិភ័យ និងអត្ថប្រយោជន៍ពាក់ព័ន្ធសម្រាប់អ្នកចូលរួម។
- ទទួលបានការជូនដំណឹងអំពីវិធីព្យាបាលវេជ្ជសាស្ត្រ ប្រសិនបើមានសម្រាប់អ្នកចូលរួម បន្ទាប់ពីចប់ការពិសោធន៍ ក្នុងករណីមានផលវិបាកកើតឡើង។
- ទទួលបានឱកាសសួរសំណួរពាក់ព័ន្ធនឹងការពិសោធន៍ ឬនីតិវិធីពាក់ព័ន្ធ។
- ទទួលបានការណែនាំថា អ្នកអាចដកខ្លួនចេញពីការចូលរួមនៅក្នុងការពិសោធន៍វេជ្ជសាស្ត្រ នៅពេលណាមួយក៏បាន ហើយអ្នកចូលរួមអាចបញ្ឈប់ការចូលរួមនេះដោយគ្មានការរើសអើង។
- ទទួលបានទម្រង់យល់ព្រមដែលមានចុះហត្ថលេខា និងចុះកាលបរិច្ឆេទចំនួនមួយច្បាប់។ និង
- ទទួលបានឱកាសសម្រេចចិត្តយល់ព្រម ឬមិនយល់ព្រមចំពោះការពិសោធន៍វេជ្ជសាស្ត្រដោយគ្មានអន្តរាគមន៍នៃសមាសភាពកម្លាំង ការក្លែងបន្លំ ការបោកបញ្ឆោត ការបង្ខិតបង្ខំ ឬឥទ្ធិពលមិនសមរម្យលើការសម្រេចចិត្តរបស់អ្នកចូលរួមឡើយ។